ហាមលក់

# ដំណើរផ្សងព្រេងរបស់

# តាំតាំ តំ និង អ្នកគ្រូពេទ្យ



## តើធ្វើយ៉ាងណា ដើម្បីការពារជំងឺគ្រុនចាញ់ ?

Malaria Control Project

EUROPEAN UNION
សហគមន៍អឺរ៉ុប

# អារម្ភកថា

នៅក្នុងប្រទេសកម្ពុជា ជំងឺគ្រុនចាញ់នៅតែជាបញ្ហាចំបងនៅក្នុងសុខាភិបាលសាធារណៈ ។ ក្នុងមួយឆ្នាំៗប្រជាពលរដ្ឋប្រមាណ ១៥០០០០ នាក់ កើតជំងឺគ្រុនចាញ់ ក្នុងនោះមានកុមារប្រមាណ ៣០០០០ នាក់ ។ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ក្រោមកិច្ចសហប្រតិបត្តិការ និងទ្រទ្រង់ដោយកម្មវិធីកំចាត់ជំងឺគ្រុនចាញ់កម្ពុជា-សហគមន៍អឺរ៉ុប បានផ្តួចផ្តើមផលិតរូបភាពតុក្កតាកំប្លែង ងាយយល់ សំរាប់សហគមន៍កម្ពុជាដែលកំពុងប្រឈមមុខ ។

តាមរយៈរឿងដំណើរផ្សងព្រេងរបស់ **តាំតាំ តំ និង អ្នកគ្រូពេទ្យ** ប្រិយមិត្តអ្នកអាននឹងទទួលបាននូវពត៌មានសំខាន់ៗ ដែលទាក់ទងទៅនឹងជំងឺគ្រុនចាញ់នៅក្នុងព្រះរាជាណាចក្រកម្ពុជានូវរាល់ទិដ្ឋភាពចាប់ពីវិធានការណ៍ការពារ រហូតដល់វិធីព្យាបាលជំងឺគ្រុនចាញ់ ។

ទស្សនាវដ្តីរូបភាពដែលបោះពុម្ពចំនួន ៣០០០០ ក្បាល នឹងត្រូវចែកចាយនៅក្នុងប្រទេសដោយឥតគិតថ្លៃ ក្រោមកិច្ចសហប្រតិបត្តិការជាមួយបណ្តាអង្គភាពនានា ដែលចូលរួមពាក់ព័ន្ធទៅនឹងការប្រយុទ្ធជំងឺគ្រុនចាញ់ ។

យើងសង្ឃឹមថា មិត្តអ្នកអានកំសាន្តសប្បាយជាមួយរឿងនិទាននេះ និងសូមជូនពរអោយមានសុខភាពល្អ ។

*ភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០១*

សាស្ត្រាចារ្យ អេង ហួត
*អគ្គនាយកបច្ចេកទេសសុខាភិបាល*
*ក្រសួងសុខាភិបាល*

# PREFACE

Malaria in Cambodia is one of the most important diseases and is considered by the Ministry of Health of Cambodia as a National priority.

More than 150,000 people are affected every year and 30,000 of them are children. The Ministry of Health of Cambodia and the National Malaria Centre with the support of the European Commission Malaria Control Project took the initiative to produce an easy and understandable cartoon for the Cambodian community concerned.

Through the story of 'Tam Tam, Tom and Nakkroupette' the reader will find all the necessary information concerning Malaria in Cambodia from prevention to curative aspects.

30,000 copies of this magazine will be distributed free of charge all over the country with the collaboration of various organizations involved in the fight against Malaria.

We hope you enjoy the story and wish you the best of health.

Prof. Eng Huot
*General Director for Health*
*Ministry of Health*



សំឡូត គឺជាស្រុកមួយដាច់ស្រយាលស្ថិតនៅក្នុងខេត្តបាត់ដំបង ។ ប្រជាពលរដ្ឋនៅក្នុងស្រុកនេះប្រឈមមុខនឹងឧបសគ្គជាច្រើន ដូចជាមីនកប់ក្នុងដី ផ្លូវថ្នល់មិនល្អ និងបញ្ហាសុខភាព ។

អ្នកភូមិនៅតំបន់នោះ ភាគច្រើនជាអ្នកធ្វើស្រែចំការ កាប់អុស និងរករវល្លិ ។ ពួកគេទទួលរងជំងឺឆ្លងយ៉ាងខ្លាំង ជាពិសេសជំងឺគ្រុនចាញ់ ។




តាំតាំ និងអ្នកគ្រូពេទ្យបានធ្វើដំនើរមកកាន់ស្រុកសំឡូតដោយរថយន្ត ។
មកដល់ភូមិមួយ ... តាំតាំ និងអ្នកគ្រូពេទ្យចុះពីលើរថយន្ត ។
យ៉ាងម៉េចដែរ ការធ្វើដំនើរនេះ តាំតាំ ?
មានអីបង ... ប៉ុន្តែខ្ញុំដូចជាចុកខ្នង ចុកចង្កេះដល់ហើយ ព្រោះផ្លូវរលាក់ពេក !
ឯងធ្លាប់មកលេងស្រុកសំឡូតនេះដែរ រឺទេ ?
នេះជាលើកទីមួយហើយ ។
អេ៎សំលាញ់ ! ឯងដឹកគោទៅណាហ្នឹង ?
ខ្ញុំដឹកគោទៅអោយស៊ីស្មៅនៅខាងមុខនេះ ។
កុំអាលស្រែក យើងរាប់អានមិត្តយើងសិន !



ខ្ញុំឈ្មោះតាំតាំ តើឯងឈ្មោះអ្វីដែរ ?
ខ្ញុំឈ្មោះតំ ... ចុះបងស្រីខាងនោះឈ្មោះអី ហើយមកពីណាដែរ ?
ខ្ញុំឈ្មោះទេវី ... ខ្ញុំជាគ្រូពេទ្យ ... យើងទាំងពីរមកពីទីក្រុងភ្នំពេញ ។
តំលែងគោអោយស៊ីស្មៅ រួចជជែកគ្នាលេង ...
តំសំលាញ់ ! តើប្រជាជនក្នុងភូមិនេះ រកស៊ីអ្វីដែរ ?
ភាគច្រើនធ្វើស្រែចំការ ...
... ពេលទំនេរកាប់អុស និងរកវល្លិនៅក្នុងព្រៃ ។
អ៊ីចឹង អ្នកភូមិធ្លាប់ឈឺដែរ រឺទេ ?
ធ្លាប់ ... នៅភូមិក៏ឈឺ មកព្រៃក៏ឈឺ ។
ចុះពួកគាត់ធ្លាប់ឈឺអីទៅ ?
ភាគច្រើន ច្រើនគ្រុនក្តៅ គ្រុនអ្នកតា ...


ចុះជំងឺគ្រុននេះ
ធ្វើទុក្ខយ៉ាងម៉េច ?
អ្នកទាំងពីរសួរខ្ញុំច្រើនពេកហើយ ! ... ខ្ញុំមិនចង់ស្ដាប់ទេ !
ឥលូវយើងភ្នាល់គ្នា លេងខ្លាធ្លាក់អណ្ដូងវិញ ។
បើខ្ញុំចាញ់ ខ្ញុំព្រមស្ដាប់ឯងទៀត ...
តោះ !
លេងក៏លេង!
ហាសៗហ៎! តាំតាំ ចាញ់ខ្ញុំហើយ!
ចាញ់ក៏ចាញ់!
ពួកខ្ញុំសុំលេងម្ដងទៀត ។
យល់ព្រមប៉ុន្មានក៏មិនខ្លាចដែរ!
ម្ដងនេះ ឯងចាញ់ហើយ !
ចុះជំងឺគ្រុននេះ
យ៉ាងម៉េច ?
បាន យល់ព្រម
ឯងសួរទៀតចុះ !



ខ្ញុំលឺគេថា គ្រុននេះ
បណ្ដាលមកពីចាញ់
ទឹកចាញ់ដី ខុសអ្នកតា
នៅពេលដែលពួកគេ
ចូលទៅក្នុងព្រៃ ។
តាមទំលាប់ នៅពេលឈឺ
អ្នកភូមិច្រើនធ្វើអី ?
គេតែងតែទៅបន់ស្រន់អ្នកតា
រឺទៅរកថ្នាំតាចាន់គ្រូបុរាណ
ចុមយក្ស !
នឹកដើមអ្នកតា
ស្អីមកខាំភ្លាម !
ស្អីខាំគំ ?
ទេ មិនដឹងជាសត្វអីទេ !
បង ! នៅលើអាវយឺតបង
ម្ដេចមានរូបស្រីដេកក្នុងមុងអ៊ីចឹង ?
គឺដើម្បីការពារ
ជំងឺគ្រុនចាញ់ហ្នឹងណា៎ !
ស្អីទៅបង
ជំងឺគ្រុនចាញ់ ?






# តាំតាំ និងអ្នកគ្រូពេទ្យមកដល់ផ្ទះតាំ




តំតើឯងធ្លាប់ឈឺទេ ?
ធ្លាប់ក្តៅរងា ឈឺក្បាលដែរ !
អ៊ីចឹងកាលនោះ ឯងធ្លាប់ធ្វើយ៉ាងម៉េចដែរ ?
ខ្ញុំមិនដឹងដែរ ប៉ុន្តែម៉ែបន់ស្រន់ ហើយខ្ញុំផឹកថ្នាំបុរាណបន្តិចបន្តួចក៏ជាទៅ ...
តំដឹងទេ ! ជំងឺគ្រុនចាញ់កើតឡើងដោយសារមូសដែកគោលញីខាំ ។
ទេ ! មូសមិនដែលខាំខ្ញុំផង ភ្ញាក់ពីដេកឡើងឃើញកន្ទួលតែម្តង !
តាមពិតមូសនេះបានខាំឯងហើយ ព្រោះមូសនេះមិនបញ្ចេញសំលេងទេ ហើយខាំក៏មិនឈឺដែរ ។
អ៊ីចឹងមូសនេះខាំមិនឈឺទេ ?
ពិតមែនហើយ !
មកក្មួយៗនាំគ្នាញុំបាយ !
អ្នកមីងធ្វើម្ហូបឆ្ងាញ់ណាស់ !
អរគុណហើយក្មួយ នាំគ្នាញាំអោយបានច្រើនទៅ !
អ្នកទាំងអស់នាំគ្នាញុំបាយ ...




ក្មួយមកលេង រឺមកធ្វើការ ?
ចាស ! មកធ្វើការផង ដើរលេងផង ។
យប់នេះក្មួយសំរាកនៅឯណា ?
យប់នេះគាត់សំរាកផ្ទះយើង ព្រោះគាត់ចង់ចូលព្រៃជាមួយពុកដែរថ្ងៃស្អែក ។
តើខ្ញុំទាំងពីរនាក់អាចទៅជាមួយពូបានទេ ?
បានទេពូ ?
មានអី បើក្មួយៗចង់ទៅ ...
ពេលចូលព្រៃពូយកមុងទៅទេ ?
មិនដែលយកទៅទេ ទុកនៅតែផ្ទះ ។
ពូគួរយកវាទៅ ព្រោះអាចការពារមិនអោយមូសខាំយើងបាន ។
ចុះបើមូសខាំ អាចអោយកើតជំងឺអី ?
កើតជំងឺគ្រុនចាញ់ណាំមីង !





# តាំតាំ និងអ្នកគ្រូពេទ្យនៅក្នុងព្រៃ




អ៊ុចឹងឯងសាកថ្នាំនេះវិញមើល៍ បន្តិចទៀតបានធូរហើយ !
អរគុណបង !
ឪពុកតំបររទេះទៅមុខទៀត ...
មកដល់ព្រៃធំ ...
តំ ម៉េចធូរបន្តិច ទេ ?
ដូចជាស្វាងជាងមុន ថ្នាំបងពូកែជាងថ្នាំតាចាន់ទៀត !
ម៉ោះ ! ក្មួយៗចុះមក ! ដល់ហើយ !
អ្នកបររទេះដោះគោចេញពីនឹម រួចទៅកាប់អុស បោចវល្លិ ជាក្រុមៗ ...
ចំនែកអ្នកទាំងបីនៅមើលគោ





អេ៎តំ ! ដើមអីក៏ធំម្ល៉េះ ?
គឺដើមធ្នង់ ។
អេ៎តាំតាំ ! មើលសត្វទន្សាយនេះ ស្អាតគួរអោយស្រលាញ់មែនទែន !
ស្អាតណាស់! ប៉ុន្តែបងមើលសត្វសេកនេះវិញ... វាកំពុងតែស៊ីផ្លែឈើ...
ពេលយប់មកដល់ ...
ដាក់អុសអោយច្រើនមក !
អ្នករកអុស និងបោចវល្លិ នាំគ្នាបំពក់ភ្លើងក្បែរគោ រួចរៀបចំកន្លែងសំរាក ។
ពូ ! ពូសំរាន្តលក់ហើយ រឺនៅ ?
នៅទេ ...
ហេតុអ្វីបានពូមិនសំរាន្តក្នុងមុង ?
ពូមិនខ្លាចមូសទេ រឺ ?
ខ្លាចអីមូសតូចមួយហ្នឹង! ពូដុតភ្លើងហើយ វាមិនហ៊ានមកជិតទេ!
ប៉ុន្តែពេលពូសំរាន្តលក់ ភ្លើងក៏រលត់ដែរ ។ ពូមិនអាចដឹងថាមូសខាំទេ ព្រោះមូសមិនបញ្ចេញសំលេង ហើយខាំក៏មិនឈឺដែរ !


ពូដឹងទេ ! មូសនៅក្នុងព្រៃសាហាវជាង មូសនៅក្នុងស្រុក ពេលវាខាំយើង យើងប្រាកដជាមានជំងឺ ។
ជំងឺអ្វីទៅ ?
គឺជំងឺគ្រុនចាញ់ណាំពូ !
កុំនិយាយលេង ពូមិនជឿទេ!
អ៊ីចឹងពូធ្លាប់ឈឺ រឺទេ ?
ធ្លាប់ដែរ គឺគ្រាន់តែក្ដៅរងា ឈឺក្បាល ហើយល្វីងមាត់ ...
ចុះពូឈឺភាគច្រើន នៅពេលណា ?
ពេលត្រលប់មកពីកាប់អុស ក្នុងព្រៃប្រហែលបួនដប់ថ្ងៃ ។
ហ្ន៎ ! ឃើញទេ ! ពូឈឺមកពីពូសំរាន្តមិនដាក់មុង ។
ទេ ! មិនអ៊ីចឹងទេ ! គ្រុនបែបនេះ គេថាគ្រុនអ្នកតា ចាញ់ទឹក ចាញ់ដី ...
ប៉ុន្តែពូត្រូវតែសំរាន្ត ក្នុងមុងប្រសើរជាង ។



# ជួបនឹងអ្នកជំងឺ


មួយអាទិត្យក្រោយមក ពូសុខស្រាប់តែក្ដៅរងា និយាយរវើរវាយផ្ដេសផ្ដាស ...
អ៊ូយក្ដៅណាស់ ! ងាប់ខ្ញុំឥលូវហើយ ...
ចេះតែយ៉ាងម៉េចពុកវា ដូចជាបែកញើស ខ្លាំងម្ល៉េះ ?
ខ្ញុំមិនដឹងជាយ៉ាងម៉េចទេនៅក្នុងខ្លួន !
កុំយំពេក អាអូន !
ប្រាកដជាឯងខុសមាត់ខុសកជាមួយ អ្នកតាហើយពេលនៅក្នុងព្រៃ ...
ផឹកថ្នាំតាចាន់នេះ ហើយ សំរាន្តទៅ ! បន្តិច ទៀតធូរហើយ ...
ខ្ញុំទៅអុជធូបបន់ស្រន់ អ្នកតាសិន ។
សូមលោកតាកុំប្រកាន់ ពាក្យសំដីប្ដីខ្ញុំអី ...


តំ តាំតាំ និងអ្នកគ្រូពេទ្យ ទៅសួរសុខទុក្ខពូសុខ័ ...
មីងកំពុងធ្វើអី ?
លើកដៃថ្វាយព្រះក្នួយទាំងអស់គ្នា! អីងបន់ស្រន់អ្នកតាអោយជួយ ពូឯង ។
គាត់ឈឺរវើរវាយ ... ប្រហែលមកពី ខុសមាត់ខុសកជាមួយអ្នកតាក៏មិនដឹង ...
ឥលូវ ពូយ៉ាងម៉េចហើយ ?
កំពុងក្តៅផង រងាផង និងរវើរវាយផង ។
នេះមិនមែនក្តៅធម្មតាទេ ពូមានជំងឺគ្រុនចាញ់ហើយ !
ទេ! មកពីខុសមាត់ ខុសកជាមួយអ្នកតាទេ!
មិនជឿទេ! ប្រាកដជាខុសមាត់ ខុសកជាមួយអ្នកតាហើយ!
មួយសន្ទុះក្រោយមក ពូសុខអន់ក្តៅ ។




ពិតមែនណាំពូ ! ព្រោះពេលចូល ព្រៃ ពូសំរាន្តមិនដាក់មុងទេ !
មែនហើយពូ !
ពូពិសាថ្នាំនេះសិនទៅ ពូនឹងបានធូរស្រាលបន្តិចហើយ ចាំទៅមណ្ឌលសុខភាព ។
មីង ជួយហៅអ្នកជិតខាងមកជួយយកគាត់ ទៅពេទ្យឥលូវនេះ !
មិនចាំបាច់ទេដឹង ក្មួយ មីងបន់ស្រន់អ្នកតាហើយ ។
មីងបន់ក៏បន់ទៅ ប៉ុន្តែត្រូវយកគាត់ទៅ មណ្ឌលសុខភាពជាដាច់ខាត !
មីងយកពូទៅមណ្ឌលកាន់តែឆាប់ គាត់កាន់តែឆាប់ធូរស្បើយ ។
នោះពុកខ្ញុំបររទេះសេះមកហើយ ... ពុកៗឈប់សិន !


មានការអីតំ ?
ពូៗ ! ជួយលើកគាត់ដាក់រទេះសេះផង !
កូននៅមើលប្អូនផង ! ម៉ែទៅជួយមើលពុកឯង !
ចាស ម៉ែ !
តោះពូ ! ចេញដំនើរទៅ !
បងពេទ្យៗ ! ចាំខ្ញុំផង ខ្ញុំទៅដែរ !
ឯងចាំទៅជាមួយគ្នា យើងទៅតាមក្រោយ !
តោះអ៊ុចឹង នាំគ្នារត់ទៅ !
អាចង្រៃនេះ ឯងប្រញាប់ វាប្រញាប់របូតដែរ !
លឿនឡើង តំ !
ចាំខ្ញុំបន្តិច ព្រោះខោខ្ញុំចេះតែរបូតចុះក្រោម !
តោះស្រួតឡើង !



# ពូសុខជាសះស្បើយ


មណ្ឌលសុខភាព
មកដល់មណ្ឌលសុខភាព ....
ពូ ជួយគ្រាហ៍គាត់ចូលមក !
តើគាត់ឈឺអ្វីដែរបាទ ?
គាត់មានជំងឺគ្រុនចាញ់ !
អោយគាត់សំរាន្តលើគ្រែនេះចុះ ! ខ្ញុំជួសឈាមគាត់យកទៅពិនិត្យ !
ចាស ! លោកគ្រូពេទ្យ !
តំ និង តាំតាំមកដល់ក្រោយគេ ...
អ៊ូយ ! ហត់ណាស់ !



អេំ ! ម៉េចឯងទាំងពីរនាក់មកយឺតម្ល៉េះ ?
សុំទោសបង! ព្រោះខោខ្ញុំចេះតែរបូត!
ពូសុខ គាត់យ៉ាងម៉េចទៅហើយ?
ពេទ្យជួសឈាមគាត់ទៅពិនិត្យហើយ ។
បន្តិចទៀតបានលទ្ធផលហើយ ។
មីងដឹងទេ ! ជំងឺគ្រុនចាញ់នេះ
បង្កឡើងដោយមូសដែកគោលញី ។
មីងដូចជាមិនសូវច្បាស់សោះ !
មួយសន្ទុះក្រោយមក លទ្ធផលបង្ហាញថាមានគ្រុនចាញ់មែន ។
ពេទ្យបានអោយថ្នាំពូសុខពិសាបន្ត ។
ពូសុខភ្ញាក់ ប៉ុន្តែហាក់ដូច
មិនទាន់ស្រួលខ្លួននៅឡើយ ។
ពូភ្ញាក់ហើយ !
ពូបានធូរខ្លះទេ ?
ឯងផើបឡើង ហូបបបរក្តៅៗនេះ
បន្តិចទៅ នឹងអាលឆាប់បានទៅផ្ទះ !





ហូបក៏ហូបដែរ !
៣ថ្ងៃក្រោយមក ពូសុខត្រលប់មកផ្ទះវិញ ...
ពុកជា
ហើយរឺនៅ?
អ្នកជិតខាងមកសួរសុខទុក្ខពូសុខ
បានធូរច្រើនហើយបង !
យ៉ាងម៉េចហើយ លោកប្អូន?
ចុះប្អូនឯងឈឺអីទៅ ?
ខ្ញុំឈឺគ្រុនចាញ់ ពេទ្យប្រាប់ខ្ញុំ ។
ប្រហែលដូចក្មួយស្រីពេទ្យបានប្រាប់ថា
មកពីមូសដែកគោលញីខាំ ពេលខ្ញុំ
ចូលព្រៃរកអុសហើយមើលទៅ !
អ៊ីចឹង មូសដែកគោលញីហ្នឹង
ខាំហើយ កើតជំងឺគ្រុនចាញ់
ពិតមែន ?
ពិតមែនហើយលោកអ៊ំ !




# ប្រសិទ្ធិភាពនៃមុងជ្រលក់ថ្នាំ





មីងមិនជឿទេ! ព្រោះកូនប្រុស
មីងឧស្សាហ៍ដេកក្នុងមុងដែរ
តែនៅ
តែឈឺ ។
ប៉ុន្តែមីងត្រូវអោយកូន
ដេកក្នុងមុងជានិច្ច
ទាំងនៅក្នុងព្រៃ
ទាំងនៅក្នុងភូមិ ។
អូយ ! គ្រាន់តែនិយាយបានហើយ
ចាំបាច់ជាន់ជើងខ្ញុំអី !
សុំទោស តំ !
ចុះពេលមិនទាន់ចូលមុង ត្រូវធ្វើដូចម៉េចខ្លះ ?
មីងត្រូវស្លៀកពាក់វែង ជិតៗ
បំពក់ភ្លើង រឺដុតធូបមូស ។
មីងដឹងទេ! មុងជ្រលក់ថ្នាំនេះមានប្រសិទ្ធិភាព
ណាស់! វាការពារជំងឺគ្រុនចាញ់ផង និង
សត្វល្អិតផង!
អ៊ីចឹង ធ្វើយ៉ាងម៉េចទៅ
ទើបបានមុងជ្រលក់ថ្នាំ ?
មីងកុំព្រួយអី ! បន្តិចទៀតខាងមន្ទីរ
សុខាភិបាលយកមកចែកហើយ !
ចុះធ្វើដូចម្តេចដើម្បីរក្សាមុងអោយបានល្អ?






ដើម្បីថែរក្សាមុងជ្រលក់ថ្នាំ ...
... មិនត្រូវបោកនឹងសាប៊ូពេលមុងប្រលាក់
... មិនត្រូវហាលថ្ងៃពេលមុងសើម
និងត្រូវបត់ទុកដាក់អោយបានត្រឹមត្រូវ
ពេលប្រើប្រាស់ហើយ ។
ពិសេសទៅទៀតនោះ មុងជ្រលក់ថ្នាំនេះ
មានប្រសិទ្ធិភាពចំនួនពី ៨ ទៅ ១០ខែ ។
អស្ចារ្យប៉ុនហ្នឹងផង
មុងជ្រលក់ថ្នាំ !
អ៊ីចឹងពេលអស់ប្រសិទ្ធិភាព
ខ្ញុំទៅរកឯងនៅឯណា ?
មិនអ៊ីចឹងទេ មន្ទីរសុខាភិបាលខេត្តមានកម្មវិធី
ជ្រលក់មុងសាឡើងវិញអោយ !
អ្ហូ ! អ៊ីចឹងទេ !
ខ្ញុំស្មានតែត្រូវទៅរកឯងនៅភ្នំពេញ !






## 'TAM TAM, TOM and NAKKROUPETTE'
## MALARIA STEERING COMMITTEE MEMBERS

H.E. Oum Chenda, Under Secretary of State, Ministry of Women's and Veteran's Affairs
Dr Mey Bouth Denis, National Co-Director, European Commission - Cambodia Malaria Control Project
Mr Roberto Garcia, European Co-Director, European Commission - Cambodia Malaria Control Project
Dr Bou Kheng Thavrin, IEC Department Manager, National Malaria Center
Ms Ket Kanha, Deputy Chief of Nutrition Office, Ministry of Women's and Veteran's Affairs
Ms Céline Serriere, Sales Manager, Graphic roots
Mr Puth Sokmean, Tam Tam Editor in Chief, Graphic roots
Mr Michael Delens, European Director, PASEC II
Mr Dy Vanly, Deputy of Technical Office, Ministry of Youth and Education
Ms Mao Leakhena, Co-Directors Assistant, European Commission - Cambodia Malaria Control Project
Mr Soeung Makara, Tam Tam Illustrator, Graphic roots
Mr Am Pheara, Executive Director, Save the Children
Mr Im Sarun, Project Assistant, Save the Children

We would like to express special thanks to Dr Doung Socheat, Dr Sean Hewitt, Mr Christophe Macquet and his team and Mr Miran Mouk for contributing their expertise, ideas and energy towards this cartoon.

**In collaboration with the Ministry of Health, Ministry of Women's and Veteran's Affairs, Ministry of Youth and Education, National Malaria Center.**

**With the financial support of the European Commission - Cambodia Malaria Control Project**

**European Commission - Cambodia Malaria Control Project**
# 50A, Street 334, Sangkat Boeung Keng Kang I, Khan Chamkarmorn, P.O. Box 91,
Phnom Penh, Cambodia.
Tel: 855-23-214 214, Fax: 855-23-214 310, E-mail: eucammal@bigpond.com.kh
Regional website: http://www.mekong-malaria.org

# ការប្រលងគូររូបភាព

បន្ទាប់ពីបានអានរឿង **ដំណើរផ្សងព្រេងរបស់ តាំតាំ តំ និង អ្នកគ្រូពេទ្យ** រហូតដល់ចប់ អ្នកអាចចូលរួមក្នុងការប្រលងគូររូបភាពស្តីអំពីជំងឺគ្រុនចាញ់ ដែលអ្នកយល់ឃើញថាល្អបំផុត សំរាប់គំនិតរបស់អ្នកនៅលើក្រដាសសដែលបានភ្ជាប់មកជាមួយនេះ ហើយឆ្លើយសំនួរទាំង ៨ ផង ។ បន្ទាប់មកអ្នកត្រូវផ្ញើរូបភាពដែលបានគូររួចនោះ មកអាសយដ្ឋានដូចខាងក្រោមអោយបានមុនថ្ងៃ ទី ៣០ ខែ មករា ឆ្នាំ ២០០២ ហើយកុំភ្លេចសរសេរអាសយដ្ឋានរបស់អ្នកអោយបានច្បាស់លាស់ ផង ។

**សូមផ្ញើរូបភាពរបស់អ្នកមក :**

អង្គការសហគមន៍អឺរ៉ុប - កម្មវិធីកំចាត់ជំងឺគ្រុនចាញ់នៅកម្ពុជា
អាសយដ្ឋានផ្ទះលេខ ៥០ អា, ផ្លូវលេខ ៣៣៤, សង្កាត់បឹងកេងកង ១,
ខ័ណ្ឌចំការមន, ប្រអប់សំបុត្រលេខ ៩១, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា ។
ទូរស័ព្ទលេខ : ៨៥៥-២៣-២១៤ ២១៤ ទូរសារលេខ : ៨៥៥-២៣-២១៤ ៣១០
ទំនាក់ទំនង : កញ្ញា ម៉ៅ លក្ខិណា

**អ្នកឈ្នះរង្វាន់ពីលេខ ១ ដល់ ១០ នឹងបានទទួលរង្វាន់ដូចខាងក្រោម :**

រង្វាន់ទី ១ : ដំនើរកំសាន្តមួយសប្តាហ៍ (មធ្យោបាយធ្វើដំនើរ ការស្នាក់នៅ និងការហូបចុក) នៅខេត្តមួយក្នុងប្រទេសកម្ពុជា អាស្រ័យលើការជ្រើសរើសរបស់អ្នក ។
រង្វាន់ទី ២ : ម៉ាញេស្តេរ៉េអូ មួយគ្រឿង
រង្វាន់ទី ៣ : នាឡិកាដៃ មួយគ្រឿង
រង្វាន់ទី ៤ : ម៉ាញ៉េម៉្វូណូ មួយគ្រឿង
រង្វាន់ទី ៥ ដល់ ១០ : មុងជ្រលក់ថ្នាំចំនួន ១០ - អាវយឺត ២ និងមួក ២ ។
រង្វាន់លួងចិត្តចំនួន ៥០ នាក់ : មុងជ្រលក់ថ្នាំចំនួន ១ - អាវយឺត ១ និងមួក ១ ។

ចូរប្អូនគូររូបភាពដែលទាក់ទងទៅនឹងជំងឺគ្រុនចាញ់ដោយគំនិតរបស់ប្អូនផ្ទាល់

## សំនួរ :

ចូរប្អូនៗគូសរង្វង់នៅត្រង់ចំលើយមួយដែលប្អូនយល់ថាត្រឹមត្រូវ (ក្នុងចំលើយទាំង ៤ មានតែមួយគត់ដែលត្រឹមត្រូវ) ។

១. តើប្រជាជននៅស្រុកសំឡូតមានមុខរបរអ្វី ?

| | |
|---|---|
| ក. ធ្វើស្រែចំការ កាប់អុស បោចវល្លិ<br>ខ. កាប់អុស កាប់ឈើ បោចវល្លិ | គ. បោចវល្លិ ធ្វើស្រែចំការ<br>ឃ. ចំលើយ ខ និង គ ត្រឹមត្រូវ |

២. តើមូសប្រភេទណា ដែលបណ្តាលអោយកើតជំងឺគ្រុនចាញ់ ?

| | |
|---|---|
| ក. មូសខ្លាញី<br>ខ. មូសគុយលីក | គ. មូសដែកគោល<br>ឃ. មូសដែកគោលញី |

៣. ពេលឈឺជំងឺគ្រុនចាញ់ តើមានអ្វីកើតឡើងខ្លះ ?

| | |
|---|---|
| ក. ក្តៅខ្លួន រងាររស្រៀវ<br>ខ. ក្តៅខ្លួន រងាររស្រៀវ ឈឺក្បាល | គ. ឈឺពោះ រាគរូស រងាររស្រៀវ<br>ឃ. រាគមូល ឈឺពោះ ឈឺក្បាល |

៤. ទំនាក់ទំនងដែលបណ្តាលអោយមានការចំលងជំងឺគ្រុនចាញ់មាន :

| | |
|---|---|
| ក. មនុស្សឈឺ មូសដែកគោលញី បរិស្ថាន<br>ខ. មូសដែកគោលញី បរិស្ថាន មនុស្សជា | គ. មនុស្សឈឺ មូសដែកគោលញី មនុស្សជា<br>ឃ. ចំលើយ ក និង ខ ត្រឹមត្រូវ |

៥. នៅពេលកើតជំងឺគ្រុនចាញ់ តើអ្នកត្រូវទៅណា ?

| | |
|---|---|
| ក. អុជធូប បន់ស្រន់អ្នកតា<br>ខ. ទៅទិញថ្នាំ លេបដោយខ្លួនឯង | គ. ទៅមណ្ឌលសុខភាពណាដែលជិតជាងគេបំផុត<br>ឃ. ទៅផ្ទះគ្រូបូរាណ រកថ្នាំបូរាណ |

៦. ដើម្បីការពារជំងឺគ្រុនចាញ់ តើអ្នកត្រូវធ្វើយ៉ាងដូចម្តេច ?

-

៧. ដើម្បីថែរក្សាមុងជ្រលក់ថ្នាំ តើអ្នកត្រូវធ្វើយ៉ាងដូចម្តេច ?

-
-
-

៨. តើប្រសិទ្ធិភាពមុងជ្រលក់ថ្នាំ មានរយៈពេលប៉ុន្មានថ្ងៃ ប៉ុន្មានខែ ?

-

| |
|---|
| ចូរសរសេរអាសយដ្ឋានរបស់ប្អូននៅទីនេះ : |


**European Commission - Cambodia Malaria Control Project**
# 50A, Street 334, Sangkat Boeung Keng Kang I, Khan Chamkarmorn, P.O. Box 91,
Phnom Penh, Cambodia.
Tel: 855-23-214 214, Fax: 855-23-214 310, E-mail: eucammal@bigpond.com.kh
Regional website: http://www.mekong-malaria.org



ចូរប្អូនរកចំនុចខុសគ្នាអោយបានចំនួន ១០ ចំនុច